# SAN DIEGO CITY SCHOOLS

SDUSD

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682

(619) 725-5506


**Carl A. Cohn**
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង

ខែ តុលា ឆ្នាំ ២០០៧

មាតាបិតា និងអ្នកអាណាព្យាបាលសិស្សជាទីរាប់អាន,

សូមអរគុណដល់លោកអ្នកដែលជាមាតាបិតាផ្តល់ការសិក្សាដល់កូនអោយបានល្អបំផុតនៅក្នុងឆ្នាំសិក្សានេះ។ ខ្ញុំមានសេចក្តីទុកចិត្តយ៉ាងខ្លាំងចំពោះលោកអ្នកបានចុះឈ្មោះកូនចូលរៀននៅតាមសាលារៀនប្រចាំក្រុងរបស់យើង ព្រមទាំងណែនាំកូនទៅរៀនឲ្យបានរាល់ថ្ងៃ។ ខ្ញុំសូមជម្រាបលោកអ្នកអោយបានជ្រាបថា យើងយកចិត្តទុកដាក់ទៅលើការណែនាំកូនលោកអ្នកធ្វើការសិក្សាអោយបានជ័យជំនះនៅតាមសាលារៀនរបស់យើងព្រមទាំងលោកអ្នកមានសេចក្តីត្រេតអរនឹងសាលារៀនរបស់យើងផងដែរ។

ដូចបានជម្រាបជូនកាលពីខែន្លងទៅនេះ តាមការសិក្សាស្រាវជ្រាវរបស់ក្រសួងអប់រំប្រចាំទីក្រុង San Diego បញ្ជាក់ឲ្យឃើញថា តាមការឆ្លើយតបនៃមាតាបិតាសិស្សចំនួនជាង ៩០ភាគរយថា សាលារៀនរបស់កូនគាត់មានសន្តិសុខ, មានការស្អាតស្អំ, បុគ្គលិកសាលារៀនរាក់ទាក់គោរពដល់មាតាបិតា ពេលគាត់អញ្ជើញទៅសាលារៀន, ណែនាំសិស្សសិក្សាបានស្មើរភាពគ្នា, ព្រមទាំងផ្តល់ការសិក្សាបានល្អជាការសំខាន់បំផុត។ មាតាបិតាចំនួន ប៉ែតសិបប្រាំបីភាគរយ មានសេចក្តីរីករាយនឹងការសិក្សារបស់កូននៅតាមសាលារៀនដែលមានការជំនួយពីលោកអ្នកជាមាតាបិតា ហើយសិស្សទាំងអស់ប្រឹងប្រែងសិក្សាបានល្អប្រសើរ។ យើងធ្វើការសម្រេចប្រតិបត្តិកិច្ចការរបស់យើងអោយបានល្អតលាស់នៅឆ្នាំសិក្សានេះ។

យើងសូមជម្រាបថា លោកអ្នកគឺជាគ្រូទីមួយដ៏សំខាន់បំផុតក្នុងឆាកជីវិតរបស់កូន។ លោកអ្នកអាចផ្តល់ការសិក្សាដល់កូនបានល្អដោយរៀបចំទីកន្លែងដ៏ស្ងាត់ល្អដល់កូនសិក្សានៅតាមផ្ទះ - ទីកន្លែងសំរាប់កូនធ្វើកិច្ចការពីសាលារៀន, រៀនអានសៀវភៅ និងរៀនសរសេរនៅតាមផ្ទះ។ ពេលសិក្សានៅតាមផ្ទះ ចូរបិតទូរទស្សន៍ ហើយកំណត់ពេលឲ្យកូនមើលទូរទស្សន៍ផងដែរ។ សិស្សដែលមើលទូរទស្សន៍តិចម៉ោងធ្វើការសិក្សាបានប្រសើរជាងសិស្សដែលមើលទូរទស្សន៍ច្រើនម៉ោង។ ជាការប្រសើរ ចូរចំណាយពេលវេលារៀនអានសៀវភៅដែលលោកអ្នកនិងកូនមានការចាប់អារម្មណ៍ជាមួយកូន, អានរឿងព្រេង, ស្តាប់កូនអានរឿងសៀវភៅឲ្យស្តាប់, ព្រមទាំងរីករាយជាមួយកូនពិគ្រោះរឿងព្រេងសៀវភៅទាំងនោះ។ ការធ្វើនេះបង្ហាញអោយឃើញថា ការសិក្សារៀនអានសៀវភៅមានសារៈសំខាន់ជាទីបំផុតចំពោះលោកអ្នក។

ការទទួលស្គាល់គ្រូកូនលោកអ្នកឲ្យបានជិតស្និតគឺជាមធ្យោបាយដ៏ល្អបំផុតក្នុងការប្រស្រ័យទាក់ទង ព្រមទាំងយល់អំពីកូនសិក្សានៅតាមសាលារៀន។ ការប្រជុំ PTA គឺជាឱកាសសំរាប់លោកអ្នកចូលរួមទទួលពត៌មានស្តីអំពី ការសិក្សារបស់កូនបាន។ ចូរចំណាយពេលវេលាចូលរួមដើម្បីជួយរៀបចំគម្រោងការសំរាប់សិស្សសិក្សានាឆ្នាំនេះ។ ខ្ញុំសូមលើកទឹកចិត្តលោកអ្នកចូលរួមជាមួយ PTA ដើម្បីលើកស្ទួយដល់ការសិក្សារបស់សាលារៀនរបស់កូនលោកអ្នកនាឆ្នាំនេះ។ គ្រួសារដែលគាំទ្រកូនសិក្សានៅតាមសាលារៀន និងធ្វើការទាក់ទងជាមួយកម្មវិធីរបស់សាលារៀនមានសារៈសំខាន់បំផុតដែលអាចជួយកូនសិក្សាអោយមានការល្អតលាស់, មានតម្លៃ, និងទទួលផលប្រយោជន៍តទៅអនាគត់។

តាមការសិក្សាស្រាវជ្រាវបង្ហាញថា សិស្សដែលញាំុអាហារជាមួយមាតាបិតារបស់ខ្លួននៅតាមផ្ទះអាចធ្វើការសិក្សាបានល្អប្រសើរជាងសិស្សដែលមិនបានញាំុអាហារជាមួយមាតាបិតារបស់ខ្លួន។ ហេតុផលដែលអាចធ្វើអោយសិស្សសិក្សាបានល្អប្រសើរគឺសិស្សនោះអាចមានឱកាសពិគ្រោះជាមួយមាតាបិតារបស់ខ្លួនបាន។សិស្សរបស់យើងធ្វើការសិក្សាជាច្រើននាពេលបច្ចុប្បន្ននេះ។ ចូរប្រាប់កូនអោយពិគ្រោះអ្វីមួយជាមួយលោកអ្នក នោះជាការប្រសើរ។

សូមឲ្យលោកអ្នក និងកូនទទួលផលប្រយោជន៍ល្អនាខែ តុលា នេះ!

ដោយក្តីរាក់ទាក់បំផុត

Carl A. Cohn
អគ្គស្នងការក្រសួងអប់រំប្រចាំក្រុង